# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់**

**លេខ**: ៥៣/១៧/ ម.ត.ឯ.ច.

ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ពិធីសម្ពោធជាផ្លូវការមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំឯកសាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលគេស្គាល់ថាជាសាលាក្តីខ្មែរក្រហមនឹងរក្សាទុកបានយ៉ាងត្រឹមត្រូវសម្រាប់កូនចៅជំនាន់ក្រោយទាំងជាតិ និងអន្តរជាតិ។ ទីតាំងនោះគឺមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ម.ត.ឯ.ច.)។ មជ្ឈមណ្ឌលនេះនឹងបើកសម្ពោធជាផ្លូវការនៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង ៩.០០ នាទីព្រឹក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានទីតាំងនៅក្នុងបរិវេណអគារមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ វត្តមានរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ ក្នុងនាមជាអ្នកតំណាងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិ អ.វ.ត.ក. ស្ថាប័នច្បាប់និងអប់រំ និង តំណាងស្ថានទូតនានាប្រចាំនៅកម្ពុជា ព្រមទាំងភ្ញៀវជាតិ និងអន្តរជាតិផងដែរ។

ម.ត.ឯ.ច.ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១៥ ស្ថិតក្រោមទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីតម្កល់ឯកសារច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមមាន ឯកសារសំណុំរឿង សេចក្តីសម្រេច សាលក្រមរបស់តុលាការ ដែលត្រូវបានចងក្រងជាឯកសារអេឡិចត្រូនិច សៀវភៅ ទស្សនាវដ្តី កាសែត ។ល។ រហូតមកដល់ពេលនេះ ម.ត.ឯ.ច. បានទទួលឯកសារសាធារណៈជាអេឡិចត្រូនិច (Soft Copy) នៃសំណុំរឿង ០០១ និងឯកសារសាធារណៈជាក្រដាស (Hard Copy) នៃសំណុំរឿង ០០១ ដែលមានឯកសារសរុបចំនួន ៧០២៦ ពីសាលាក្តីខ្មែរក្រហមរួចមកហើយ។

ឯកសារទាំងអស់នេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ជាពិសេសបេសកកម្មស្វែងរកការពិត និងយុត្តិធម៌របស់ អ.វ.ត.ក. ដែលជាសមិទ្ធិផលរួមគ្នាមួយរបស់មន្ត្រីច្បាប់ជាតិ និងអន្តរជាតិ។ លើសពីនេះ សិស្ស និស្សិត បញ្ញវ័ន្ត អ្នកច្បាប់ អ្នកជំនាញក៏អាចស្វែងយល់តាមរយៈគេហទំព័រនេះផងដែរ: www.ldc-eccc.gov.kh ។

ផ្លូវលេខ ១១២៩ & ១១៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ អ៊ីម៉ែល: info@ldc-eccc.gov.kh
St. 1129 & 1130, Phnom Penh Thmey, Sen Sok, Phnom Penh Email: info@ldc-eccc.gov.kh

ម.ត.ឯ.ច. មានកិត្តិយស សូមអញ្ជើញអ្នកសារព័ត៌មានជាតិ និងអន្តរជាតិចូលរួមក្នុងព្រឹត្តិការណ៍នេះ និងសូមមកចុះឈ្មោះនៅ ម.ត.ឯ.ច. តាមរយៈមន្ត្រីផ្នែកកិច្ចការសាធារណៈឲ្យបានមុនថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០១៧ នៅវេលាម៉ោង ១៦:៣០ នាទីរសៀល។

ចំពោះព័ត៌មានបន្ថែម៖
សូមផ្ញើទំនាក់ទំនងជាមួយ:

លោកស្រី កែវ សូនី
លេខទូរស័ព្ទដៃ: 012 802 707
អ៊ីម៉ែល: keo.sony@ldc-eccc.gov.kh

កញ្ញា ឆេង សុវណ្ណកែវ
លេខទូរស័ព្ទដៃ: 095 752 969
អ៊ីម៉ែល: chheng.sovannkeo@ldc-eccc.gov.kh